| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | បុរេគណិត |
| **ប្រធានបទ** | កុមារស្គាល់បញ្ញត្តិរង្វាស់រង្វាល់ |
| **ចំណងជើងមេរៀន** | ប្រៀបធៀបពាក្យ ធ្ងន់ និងស្រាល ដកស្រង់ចេញពី<br>" រឿងតើអ្នកពូកែអី?" ។ |
| **កម្រិត** | ទាប ៣០នាទី |
| **គោលបំណង** | កុមារចេះប្រៀបធៀប ធ្ងន់ ស្រាល។<br>កុមារយល់ពីបញ្ញត្តិទម្ងន់ ធ្ងន់ ស្រាល។ |
| **បំណិនសម្បទា** | ចលនាសាច់ដុំដៃ។ |
| **ចរិយាសម្បទា** | យកចិត្តទុកដាក់ធ្វើកិច្ចការ និងសប្បាយរីករាយ។ |
| **គ្រូបង្រៀន** (ផលិតសម្ភារឧបទេស) | ធ្វើជញ្ជីង (សូមមើលខាងក្រោម)កាត់កំប៉ុងឬកែវជ័រ<br>២ ឬច្រើន<br>ជាពីរប្រមូលវត្ថុផ្សេងៗសម្រាប់ថ្លឹង អំបិល គ្រាប់សណ្តែកដែលមានទំហំផ្សេងគ្នា<br>មៀ្ញ គម្របដប ក្រដាស ។ល។ |
| **កុមារ** | -ពន្យល់របៀបលេងដល់កុមារ។<br>-កុមារអនុវត្តម្នាក់ម្តង។ |
| **ការរៀបចំ** | រៀបចំវត្ថុសម្រាប់ដាក់ថ្លឹង ដោយរៀបចំនៅកន្លែងណាដែលកុមារៗអាចយកបាន។ |

**របៀបធ្វើជញ្ជីង៖**



**ឧបករណ៍ដែលត្រូវការ៖**

- ទំពក់ព្យួរអាវមានគន្លាក់ ប្រសិនបើវាមិនមានគន្លាក់ ចូរបិទខ្សែនៅលើទំពក់។
- ខ្សែ ឬអំបោះ
- ប្រដាប់ចោះ ឬម្ជុលសម្រាប់ចោះខ្សែតាមកំប៉ុង
- កំប៉ុងឬកែវជ័រដូចគ្នាពីរ
- កន្ត្រៃ

| | |
|---|---|
| | • ស្កុត |

**របៀបធ្វើ៖**
១. វាស់ និងកាត់ខ្សែពីរដែលមានប្រវែង ៦០សម។
២. ដេចំណុចពីរ ២-៣ សម ខាងក្រោមមាត់កំប៉ុងខាងក្រៅធានាថាចំណុចទាំងពីរ។ មានទីតាំងផ្ទុយគ្នា។
៣. ចោះប្រហោងត្រង់ចំណុចដេនីមួយៗ ហើយដាក់ខ្សែចូល។ អ្នកអាចចងខ្សែនៅលើចំណុចដេកំប៉ុង។
៤. ព្យួរជញ្ជីងលើជញ្ជាំង ដោយប្រើទំពក់ព្យួរពែង ដៃទ្វារ ឬដែកព្យួរខោអាវ។
៥. ចងខ្សែកំប៉ុងនីមួយៗ ហើយដាក់វាលើគន្លាក់ទំពក់។ ប្រសិនបើទំពក់មិនមានគន្លាក់ បិទស្កុតខ្សែនៅលើទំពក់ ដោយដាក់ឱ្យមានចម្ងាយស្មើគ្នាពីខាងចុង។ ខ្សែគួរតែអាចគាំទ្រកំប៉ុងបាន ដូចដៃធុង។
៦. ពិនិត្យកំប៉ុងឱ្យស្មើគ្នាមុនប្រើប្រាស់។

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
|---|---|---|
| ១. និយាយអំពីលោកគ្រូ សុខ ដែលមានកម្លាំងខ្លាំង ហើយមនុស្សខ្លាំងអាចលើកវត្ថុធ្ងន់ៗបាន។<br>២. សួរកុមារថាតើពួកគេស្គាល់ពាក្យ "ធ្ងន់" ដែរឬទេ។<br>៣. សួរពួកគេថាតើពួកគេស្គាល់ពាក្យផ្ទុយនឹងពាក្យ "ធ្ងន់" ឬទេ។<br>៤. ឱ្យកុមារផ្តល់ឧទាហរណ៍មួយចំនួន អំពីវត្ថុធ្ងន់ និងស្រាល។<br>៥. ណែនាំពាក្យប្រៀបធៀបទាំងនេះ៖ ធ្ងន់ជាង ធ្ងន់ជាងគេ ស្រាលជាង ស្រាលជាងគេ។<br>៦. ពន្យល់អំពីរបៀបលេងល្បែងទៅកាន់កុមារ។<br>៧. ឱ្យកុមារជ្រើសរើសវត្ថុមួយនៅក្នុងថ្នាក់រៀនសម្រាប់ថ្លឹង។ | វិធីសាស្ត្រ៖<br>១. ឱ្យកុមារម្នាក់ដាក់វត្ថុមួយចូលទៅក្នុងកំប៉ុងជញ្ជីងពាក់កណ្តាល។<br>២.ឱ្យកុមារម្នាក់ទៀត ជ្រើសរើសវត្ថុមួយទៀតហើយដាក់ចូលក្នុងកំប៉ុងជញ្ជីងដដែលពាក់កណ្តាលទៀត។<br>៣. ពិភាក្សាជាមួយកុមារតើកំប៉ុងជញ្ជីងខាងណាដែលពួកគេគិតថាធ្ងន់ជាង ហើយហេតុអ្វី?<br>៤. ឱ្យកុមារម្នាក់ដាក់វត្ថុចូលទៅក្នុងកំប៉ុងជញ្ជីងទីពីរ។<br>៥. ពិភាក្សាអំពីលទ្ធផលជាមួយកុមារៗ។ ហេតុអ្វីបានជាពួកគេគិតថាកំប៉ុងជញ្ជីងនោះធ្ងន់ជាង ឬស្រាលជាង?<br>៦. បន្តការពិភាក្សា ដោយអាស្រ័យលើចម្លើយរបស់កុមារៗ។ | ១. ចូរស្តាប់អ្នកគ្រូ/លោកគ្រូយ៉ាងយកចិត្តទុកដាក់។<br>២. ចូរពន្យល់ពីនិយមន័យនៃពាក្យ ប្រសិនបើអ្នកដឹង។<br>៣. ផ្តល់ឧទាហរណ៍ ប្រសិនបើអាច។<br>៤. ធ្វើតាមការណែនាំរបស់អ្នកគ្រូ/លោកគ្រូដោយប្រុងប្រយ័ត្ន ដោយមិនឱ្យកំពប់វត្ថុសម្រាប់ថ្លឹងឡើយ។<br>៥. ចូរឆ្លើយសំណួរអ្នកគ្រូ/លោកគ្រូ។ |